ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.០១៨.០០៩ ប្រ.ក.ព.ម

ថ្ងៃសុក្រ ៦កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨

## សេចក្តីប្រកាសព័ត៌មាន
## អំពីសិក្ខាសាលាស្តីពី " សារៈសំខាន់នៃការចងក្រងស្ថិតិ "

នៅថ្ងៃសុក្រ ៦កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ នៅសណ្ឋាគារភ្នំពេញ ធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី **"សារៈសំខាន់នៃការចងក្រងស្ថិតិ"** ក្នុងគោលបំណងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីអត្ថប្រយោជន៍នៃការចងក្រង និងការប្រើប្រាស់ស្ថិតិ ក្រោមអធិបតីភាព លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ដោយមានអ្នកចូលរួមសរុបប្រមាណ ២០០នាក់ ដែលអញ្ជើញមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល អ្នករៀបចំគោលនយោបាយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សមាគមពាក់ព័ន្ធ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ អ្នកសិក្សាស្រាវជ្រាវ និស្សិត វិនិយោគិន និងវិស័យឯកជនផ្សេងទៀត។

សិក្ខាសាលានេះធ្វើឡើងដោយឈរលើទស្សនវិស័យចម្បង៣គឺ ៖ i/- តម្រូវការប្រើប្រាស់ទិន្នន័យ ៖ ការវិវឌ្ឍនិងសមាហរណកម្មសេដ្ឋកិច្ចបានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាកាន់តែមានភាពប្រទាក់ក្រឡារវាងកំណើន ស្ថិរភាព និងហានិភ័យ ដែលទាមទារឱ្យមានប្រព័ន្ធស្ថិតិរឹងមាំ គ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា សម្រាប់ធ្វើការវិភាគ វាយតម្លៃ ចេញវិធានការណ៍ និងរៀបចំផែនការនិងយុទ្ធសាស្រ្តអភិវឌ្ឍន៍ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ii/- គុណភាព និងវិសាលភាពទិន្នន័យ ៖ ការពង្រឹងគុណភាព និងវិសាលភាពទិន្នន័យ ត្រូវតែធ្វើឡើងជាប្រចាំ ដើម្បីឆ្លើយតបទៅតាមការអភិវឌ្ឍនិងសមាហរណកម្មសេដ្ឋកិច្ច សុខដុមនីយកម្មស្ថិតិថ្នាក់ជាតិនិងអន្តរជាតិ និងតម្រូវការរបស់អ្នកប្រើប្រាស់ និង iii/- ប្រភពផ្គត់ផ្គង់ទិន្នន័យ ៖ ប្រភពផ្គត់ផ្គង់ទិន្នន័យ គឺជាបុរេលក្ខខណ្ឌចាំបាច់ដែលធានាពីស្ថិរភាពក្នុងការផលិត និងផ្សព្វផ្សាយស្ថិតិ។ ការប្រាស្រ័យទាក់ទងគ្នានិងការយល់ពីគ្នាទៅវិញទៅមករវាងប្រភពផ្គត់ផ្គង់ទិន្នន័យ អ្នកចងក្រងទិន្នន័យ និងអ្នកប្រើប្រាស់ទិន្នន័យ គឺជាគន្លឹះជោគជ័យនៃការអភិវឌ្ឍវិស័យស្ថិតិប្រកបដោយចីរភាព និងសុខុមាលភាព។

សិក្ខាសាលានេះបានប្រព្រឹត្តទៅដោយជោគជ័យ និងផ្លែផ្កា ដោយមានការពិភាក្សាយ៉ាងផុលផុសលើប្រធានបទដែលវាគ្មិនកិត្តិយសបានធ្វើបទបង្ហាញ។ ការណ៍នេះសបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់អំពីតម្លៃ និងតួនាទីដ៏សំខាន់នៃស្ថិតិក្នុងសេដ្ឋកិច្ច និងសង្គមជាតិ។

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧